# សុន្ទរកថារបស់ឯកឧត្តម MIKAMI MASAHIRO ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីប្រគល់ទទួលសម្ភារៈបរិក្ខារពេទ្យក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុន ដើម្បីប្រយុទ្ធប្រឆាំងនឹងការឆ្លងវីរុសកូរ៉ូណាប្រភេទថ្មី

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

- សូមគោរពឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- សូមគោរពលោកស្រី វេជ្ជបណ្ឌិត Li Ailan តំណាងអង្គការ WHO ប្រចាំកម្ពុជា
- សូមគោរព ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានធ្វើការប្រគល់ជំនួយសម្ភារៈបរិក្ខារពេទ្យដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុនដើម្បីប្រយុទ្ធប្រឆាំងនឹងការឆ្លងវីរុសកូរ៉ូណាប្រភេទថ្មី (Covid-19)។

ជាបឋម ទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងនឹងការឆ្លងវីរុសCovid-19 ខ្ញុំសូមសំដែងនូវការគោរពនិងដឹងគុណចំពោះការយោគយល់និងការរួមចំណែកដ៏ធំធេងរបស់សម្តេចតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាគីពាក់ព័ន្ធ និងប្រជាជនកម្ពុជាទាំងអស់សម្រាប់ការទទួលស្វាគមន៍នាវាទេសចរណ៍ MS Westerdam ដែលអ្នកដំណើរជាច្រើនរួមទាំងជនជាតិជប៉ុនផងដែរបានធ្វើដំណើរ និងការខិតខំប្រឹងប្រែងដើម្បីសម្រួលដល់អ្នកដំណើរទាំងអស់ឲ្យវិលត្រឡប់ទៅប្រទេសកំណើតវិញ។

ជាផ្នែកមួយ នៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលជប៉ុន ក្នុងការប្រយុទ្ធប្រឆាំងនឹងការឆ្លងវីរុស(covid-19) និងជាការឆ្លើយតបទៅនឹងសំណូមពររបស់រាជរដ្ឋាភិបាលកម្ពុជា ថ្ងៃនេះរដ្ឋាភិបាល ជប៉ុនបានផ្តល់ អាវបំពង់ អាកុលសម្អាតដៃ វ៉ែនតាការពារសុវត្ថិភាព និងស្រោមដៃជាដើមដល់កម្ពុជា។ សម្ភារៈបរិក្ខារទាំងនេះគឺជាការឧបត្ថម្ភរបស់រដ្ឋាភិបាលជប៉ុន ហើយត្រូវបានមូលនិធិអាស៊ី-អឺរ៉ុប(ASEF)ស្តុកទុកនៅប្រទេសសិង្ហបុរីផ្អែកលើគំនិតផ្តួចផ្តើម ASEM សម្រាប់ការទប់ស្កាត់ជំងឺផ្តាសាយរាតត្បាតឆាប់រហ័សក្រោមកិច្ចប្រជុំអាស៊ី - អឺរ៉ុប (ASEM) ។ សម្ភារៈទាំងនេះត្រូវបានផ្ញើមកដល់កម្ពុជា ក្រោមការសម្របសម្រួលពីការិយាល័យអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិចខាងលិច(WPRO)។ ខ្ញុំសង្ឃឹមថាសម្ភារៈបរិក្ខារទាំងនេះនឹងជួយដល់តាគីពាក់ព័ន្ធផ្នែកសុខាភិបាលនៅកម្ពុជាដែលប្រយុទ្ធប្រឆាំងជាមួយនឹងវីរុសនេះ។

ដើម្បីបង្ការការរីករាលដាលនៃមេរោគនេះបន្ថែមទៀត ប្រទេសនីមួយៗចាំបាច់ណាស់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាច្រើនៗ ខ្ញុំសង្ឃឹមថាយើងនឹងអាចពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលកម្ពុជានិងអង្គការសុខភាពពិភពលោកជាដើមៗ ប្រសិនបើមានតម្រូវការជំនួយបន្ថែមទៀតនៅពេលអនាគត យើងនឹងពិចារណាយ៉ាងសកម្មៗ

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថាតាមរយៈកិច្ចសហប្រតិបត្តិការនេះ ចំណងមិត្តភាពរវាងប្រជាជនកម្ពុជានិងប្រជាជនជប៉ុននឹងកាន់តែស៊ីជម្រៅថែមមួយកម្រិតទៀតៗ

សូមអរគុណ!